# ថ្នាំបង្ការជំងឺ COVID-19 - សំណួរដែលបានសួរជាញឹកញាប់
## ការទទួលចាក់ថ្នាំបង្ការ

### តើខ្ញុំអាចចាក់ថ្នាំបង្ការបានដោយរបៀបណាខ្លះ?

ថ្នាំបង្ការអាចរកបាននៅទីតាំងរាប់រយកន្លែងនៅទូទាំងខោនធី LA ដែលរួមមានដូចជា គ្លីនិក ឱសថស្ថាន សាលារៀន និងទីតាំងក្នុងសហគមន៍ផ្សេងទៀត។ ការចាក់ថ្នាំបង្ការនៅតាមផ្ទះក៏មានផ្តល់ជូនផងដែរសម្រាប់មនុស្សដែលមិនអាចធ្វើដំណើរចេញពីផ្ទះបាន។ ទីតាំងជាច្រើនមិនតម្រូវចាំបាច់ឱ្យធ្វើការណាត់ជួបទេ។

ដើម្បីស្វែងរកទីតាំងមួយ សូមចូលទៅកាន់គេហទំព័រ ph.lacounty.gov/howtogetvaccinated។ ប្រសិនបើអ្នកត្រូវការជំនួយ អ្នកអាចទូរស័ព្ទទៅ **មជ្ឈមណ្ឌលផ្តល់ព័ត៌មានទាក់ទងនឹងថ្នាំបង្ការរបស់នាយកដ្ឋានសុខភាពសាធារណៈ (DPH)** តាមរយៈលេខ **1-833-540-0473** ដែលមានបម្រើការជូន 7 ថ្ងៃក្នុងមួយសប្តាហ៍ ចាប់ពីម៉ោង 8 ព្រឹកដល់ម៉ោង 8:30 យប់។ ពួកគេអាចរៀបចំការចាក់ថ្នាំបង្ការនៅតាមផ្ទះ ឬការដឹកជញ្ជូនទៅកាន់ទីតាំងចាក់ថ្នាំបង្ការ ឬក៏ជួយរៀបចំមធ្យោបាយធ្វើដំណើរនិងសេវាកម្មផ្សេងទៀតសម្រាប់ជនពិការផងដែរ។ អ្នកក៏អាចស្នើសុំការចាក់ថ្នាំបង្ការនៅតាមផ្ទះ នៅលើគេហទំព័រ ph.lacounty.gov/vaxathome។ ព័ត៌មានក៏អាចរកបានជាច្រើនភាសា 24 ម៉ោងក្នុងមួយសប្តាហ៍ ដោយទូរស័ព្ទទៅកាន់លេខ 2-1-1។

### តើខ្ញុំនឹងត្រូវចំណាយប្រាក់ដើម្បីទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 ដែរឬទេ?

ទេ។ ប្រសិនបើអ្នកមានធានារ៉ាប់រងនោះ គ្រូពេទ្យឬឱសថស្ថានរបស់អ្នក អាចគិតថ្លៃចំណាយពីក្រុមហ៊ុនធានារ៉ាប់រងរបស់អ្នកសម្រាប់ការផ្តល់ថ្នាំបង្ការ។ មនុស្សទាំងឡាយដែលមិនមានធានារ៉ាប់រងសុខភាពក៏អាចទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 បានដោយមិនគិតថ្លៃផងដែរ។ មិនមានការចំណាយប្រាក់ចេញពីហោប៉ៅផ្ទាល់នោះទេសម្រាប់បុគ្គលណាក៏ដោយ។

### តើខ្ញុំនឹងមានការសួរនាំអំពីស្ថានភាពអន្តោប្រវេសន៍របស់ខ្ញុំ នៅពេលដែលខ្ញុំទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 ដែរឬទេ?

ទេ។ ថ្នាំបង្ការជំងឺ COVID-19 កំពុងមានការផ្តល់ជូនដោយមិនគិតថ្លៃ ហើយដោយមិនគិតអំពីស្ថានភាពអន្តោប្រវេសន៍ឡើយ។ ព័ត៌មានផ្នែកសុខភាពរបស់អ្នកគឺរក្សាជាការសម្ងាត់ ហើយការទទួលចាក់ថ្នាំបង្ការ COVID-19 មិនប៉ះពាល់ដល់ស្ថានភាពអន្តោប្រវេសន៍របស់អ្នកនោះទេ។ អ្នកមិនត្រូវការប័ណ្ណសម្គាល់ខ្លួនដែលបានចេញដោយរដ្ឋាភិបាល ឬក៏លិខិតពីម្ចាស់អាជីវកម្មឬកន្លែងការងាររបស់អ្នកដើម្បីទទួលចាក់ថ្នាំបង្ការនោះទេ។ សម្រាប់សំណួរអំពីផ្នែកអន្តោប្រវេសន៍ សូមចូលទៅកាន់គេហទំព័រ oia.lacounty.gov របស់ការិយាល័យកិច្ចការជនអន្តោប្រវេសន៍ (Office of Immigrant Affairs) ឬទូរស័ព្ទទៅកាន់លេខ 800-593-8222។

### តើខ្ញុំត្រូវផ្តល់លេខទូរស័ព្ទចល័ត ឬអាសយដ្ឋានអ៊ីម៉ែល ដែរឬទេ?

ទេ។ នៅពេលអ្នកទទួលចាក់ថ្នាំបង្ការ នឹងមានការស្នើសុំឱ្យអ្នកផ្តល់អាសយដ្ឋានអ៊ីម៉ែល ឬលេខទូរស័ព្ទចល័ត។ ព័ត៌មាននេះនឹងត្រូវបញ្ចូលទៅក្នុងបញ្ជីឈ្មោះការចាក់ថ្នាំបង្ការទូទៅរបស់រដ្ឋកាលីហ្វ័រញ៉ា (CAIR) ដូច្នេះអ្នកអាចទទួលបានកំណត់ត្រានៃការចាក់ថ្នាំបង្ការជំងឺ COVID-19 ជាលក្ខណៈឌីជីថលបាន។ ព័ត៌មាននេះក៏អាចនឹងមានការប្រើប្រាស់ដើម្បីផ្ញើការរំលឹក ប្រសិនបើដល់ពេលកំណត់ឱ្យមកទទួលចាក់ដូសនៃថ្នាំបង្ការជំងឺ COVID-19 បន្ថែមទៀតផងដែរ។ កំណត់ត្រានៃការចាក់ថ្នាំបង្ការជាលក្ខណៈឌីជីថលនេះ គឺជាវិធីដែលមិនគិតថ្លៃ និងមានភាពងាយស្រួលមួយដើម្បីបញ្ជាក់អំពីស្ថានភាពនៃការចាក់ថ្នាំបង្ការរបស់អ្នក។ ការធ្វើបែបនេះមានផលប្រយោជន៍ជាពិសេសប្រសិនបើអ្នកបាត់បង់កាតចាក់ថ្នាំបង្ការពណ៌សរបស់អ្នក។ អ្នកមិនចាំបាច់ផ្តល់អាសយដ្ឋានអ៊ីម៉ែល ឬលេខទូរស័ព្ទផ្ទាល់ខ្លួនរបស់អ្នកដើម្បីទទួលចាក់ថ្នាំបង្ការ ប៉ុន្តែការមិនផ្តល់ព័ត៌មាននេះ អាចធ្វើឱ្យមានការពិបាកជាងមុនក្នុងការទទួលបានកំណត់ត្រានៃការចាក់ថ្នាំបង្ការជាលក្ខណៈឌីជីថលនៅពេលក្រោយ។ អ្នកអាចស្វែងយល់បន្ថែមអំពីកំណត់ត្រានៃការចាក់ថ្នាំបង្ការជាលក្ខណៈឌីជីថល នៅលើគេហទំព័រ myvaccinerecord.cdph.ca.gov ហើយនិងអំពីការរក្សាការសម្ងាត់ នៅទីនេះ។

### តើខ្ញុំអាចទទួលបានច្បាប់ចម្លងនៃកំណត់ត្រាការចាក់ថ្នាំបង្ការរបស់ខ្ញុំនៅទីណាខ្លះ?

កាតកំណត់ត្រានៃការចាក់ថ្នាំបង្ការជំងឺ COVID-19 របស់មជ្ឈមណ្ឌលគ្រប់គ្រងនិងទប់ស្កាត់ជំងឺឆ្លង (CDC) (កាតពណ៌ស) គឺជាភស្តុតាងផ្លូវការនៃការចាក់ថ្នាំបង្ការ។ មនុស្សគ្រប់រូបគួរតែទទួលបានកាតនេះមួយសន្លឹក នៅពេលដែលពួកគេទទួលចាក់ថ្នាំបង្ការ។ **សូមរក្សាទុកកាតនេះឱ្យមានសុវត្ថិភាព ពីព្រោះមិនអាចមានកាតជំនួសនោះទេ។** គួរពិចារណាថតរូប ឬថតចម្លងកាតនេះទុក។

មនុស្សគ្រប់រូប* ដែលបានទទួលចាក់ថ្នាំបង្ការនៅក្នុងរដ្ឋ California អាចស្នើសុំកំណត់ត្រានៃការចាក់ថ្នាំបង្ការជំងឺ COVID-19 ជាលក្ខណៈឌីជីថលបាន តាមរយៈគេហទំព័រ myvaccinerecord.cdph.ca.gov។ កំណត់ត្រាជាលក្ខណៈឌីជីថលនេះក៏ជាកំណត់ត្រាផ្លូវការផងដែរ។ អាចមានការទាញយកកំណត់ត្រានេះសម្រាប់ដាក់នៅក្នុងកាបូបឌីជីថល

(digital wallet) របស់កម្មវិធី Google Pay នៅលើទូរស័ព្ទប្រភេទ Android ឬក៏កម្មវិធី Apple Health នៅលើទូរស័ព្ទម៉ាក iPhone ផងដែរ។ អ្នកក៏អាចថតផ្ទៃអេក្រង់ (screenshot) កំណត់ត្រានៃការចាក់ថ្នាំបង្ការជំងឺ COVID-19 ជាលក្ខណៈឌីជីថលរបស់អ្នក ហើយរក្សារូបភាពនោះនៅក្នុងប្រអប់រក្សារូបភាព (camera roll) ក្នុងទូរស័ព្ទរបស់អ្នកបានផងដែរ។ អ្នកអាចទទួលបានកំណត់ត្រាសម្រាប់មនុស្សម្នាក់ៗនៅក្នុងក្រុមគ្រួសាររបស់អ្នក បើទោះបីជាអ្នកបានប្រើប្រាស់អាសយដ្ឋានអ៊ីម៉ែល ឬលេខទូរស័ព្ទចល័តដូចគ្នាក៏ដោយ នៅពេលដែលពួកគេបានទទួលចាក់ថ្នាំបង្ការនោះ។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ កំណត់ត្រានៃការចាក់ថ្នាំបង្ការ។

*ប្រសិនបើអ្នកបានទទួលចាក់ថ្នាំបង្ការដោយទីភ្នាក់ងាររបស់រដ្ឋាភិបាល (ឧទាហរណ៍ ក្រសួងការពារជាតិ សេវាកម្មសុខភាពជនជាតិដើមឥណ្ឌា ឬកិច្ចការអតីតយុទ្ធជន/Department of Defense, Indian Health Service or Veterans Affairs) អ្នកត្រូវតែស្នើសុំកំណត់ត្រានៃការចាក់ថ្នាំបង្ការពីទីភ្នាក់ងារនោះដោយផ្ទាល់តែម្តង។

## តើខ្ញុំត្រូវតែផ្តល់ការអនុញ្ញាតដើម្បីឱ្យកូនរបស់ខ្ញុំអាចទទួលចាក់ថ្នាំបង្ការបាន មែនឬទេ?

យុវវ័យដែលមានអាយុក្រោម 18 ឆ្នាំត្រូវមានការអនុញ្ញាតពីឪពុកម្តាយ/អាណាព្យាបាល ឬអ្នកផ្តល់ការថែទាំ ដើម្បីទទួលចាក់ថ្នាំបង្ការ។ ប្រសិនបើអ្នកមិនអាចមានវត្តមានទេនោះ អ្នកអាចផ្តល់ការអនុញ្ញាតតាមទូរស័ព្ទ វីដេអូ ឬជាលាយលក្ខណ៍អក្សរបាន។ សូមពិនិត្យមើលតម្រូវការចាំបាច់ទាំងឡាយនៃការផ្តល់ការអនុញ្ញាត នៅតាមទីតាំងដែលអ្នកមានគម្រោងនឹងទៅ។ ប្រសិនបើនោះជាទីតាំងដែលគ្រប់គ្រងដោយនាយកដ្ឋានសុខភាពសាធារណៈ (Public Health) អ្នកអាចរកមើលតម្រូវការចាំបាច់ទាំងឡាយ និងទាញយកបែបបទនៃការអនុញ្ញាតបានតាមរយៈគេហទំព័រ ph.lacounty.gov/vaccineappointment - ដោយចុចលើ 'ការត្រៀមខ្លួនសម្រាប់ដំណើរទៅរបស់អ្នក (Preparing for your visit)" ឬទូរស័ព្ទទៅមជ្ឈមណ្ឌលផ្តល់ព័ត៌មានទាក់ទងនឹងថ្នាំបង្ការ តាមរយៈលេខ 1-833-540-0473 (មានបម្រើការជូនចាប់ពីម៉ោង 8 ព្រឹក ដល់ម៉ោង 8:30 យប់ ជារៀងរាល់ថ្ងៃ)។

ករណីលើកលែងមួយចំនួននឹងត្រូវអនុវត្ត។ អនីតិជន (ជនមិនទាន់គ្រប់អាយុ) ដែលមានអាយុចាប់ពី 15 ឆ្នាំឡើងទៅ ហើយដែលអាចទទួលខុសត្រូវដោយខ្លួនឯងបាន (ឧទាហរណ៍ ជាអនីតិជនដែលមានសិទ្ធិស្របច្បាប់ឬដែលអាចទទួលខុសត្រូវដោយខ្លួនឯងបាន ឬបានរៀបការរួចហើយ ឬក៏ធ្លាប់បានរៀបការពីពេលមុន) អាចផ្តល់ការអនុញ្ញាតដោយខ្លួនឯងបាន។ ប្រសិនបើអ្នកជាអ្នកចិញ្ចឹមមើលថែទាំ ឬជាសាច់ញាតិមើលថែទាំ ឬក៏ជាបុគ្គលិកកម្មវិធីព្យាបាលឱ្យស្នាក់នៅរយៈពេលខ្លី (STRTP) អ្នកអាចផ្តល់ការអនុញ្ញាតបានផងដែរ ដរាបណាកុមារចិញ្ចឹមនោះយល់ព្រម។ ប្រសិនបើអ្នកគឺជាអ្នកចិញ្ចឹមមើលថែទាំ ហើយអ្នកមិនផ្តល់ការអនុញ្ញាតទេ ប៉ុន្តែកូនចិញ្ចឹមរបស់អ្នកចង់ទទួលចាក់ថ្នាំបង្ការនោះ ពួកគេអាចទាក់ទងទៅអ្នកប្រឹក្សាខាងច្បាប់របស់ពួកគេបាន។

## តើខ្ញុំត្រូវការយកឯកសារអ្វីខ្លះទៅជាមួយ ដើម្បីចាក់ថ្នាំបង្ការសម្រាប់កូនរបស់ខ្ញុំ?

ទីតាំងចាក់ថ្នាំបង្ការមួយចំនួនអាចតម្រូវចាំបាច់ឱ្យមានប័ណ្ណសម្គាល់ខ្លួនដែលមានរូបថត។ ប្រសិនបើអ្នកគឺជាអាណាព្យាបាលរបស់កុមារដែលស្ថិតក្រោមការចិញ្ចឹមមើលថែទាំ ហើយកូនចិញ្ចឹមរបស់អ្នកមិនមានប័ណ្ណសម្គាល់ខ្លួនដែលមានរូបថតទេនោះ សូមឱ្យពួកគេទាក់ទងទៅអ្នកប្រឹក្សាខាងច្បាប់របស់ពួកគេ។ ជម្រើសមួយទៀត គឺត្រូវទៅកាន់ទីតាំងមួយដែលគ្រប់គ្រងដោយនាយកដ្ឋានសុខភាពសាធារណៈនៃខោនធី Los Angeles ដែលមិនតម្រូវចាំបាច់ឱ្យមានប័ណ្ណសម្គាល់ខ្លួនដែលមានរូបថតទេនោះ។

សូមមើលផ្នែកខាងលើ សម្រាប់ព័ត៌មានអំពីការអនុញ្ញាត។ សូមពិនិត្យមើលតម្រូវការចាំបាច់ទាំងឡាយនៅតាមទីតាំងដែលអ្នកមានគម្រោងនឹងទៅ។ សម្រាប់តម្រូវការចាំបាច់ទាំងឡាយនៅតាមទីតាំងចាក់ថ្នាំបង្ការរបស់នាយកដ្ឋានសុខភាពសាធារណៈនៃខោធី LA សូមចូលទៅកាន់គេហទំព័រ ph.lacounty.gov/vaccineappointment - ដោយចុចលើ "ការត្រៀមខ្លួនសម្រាប់ដំណើរទៅរបស់អ្នក (preparing for your visit)" ឬទូរស័ព្ទទៅមជ្ឈមណ្ឌលផ្តល់ព័ត៌មានទាក់ទងនឹងថ្នាំបង្ការ តាមរយៈលេខ 1-833-540-0473 (មានបម្រើការជូនចាប់ពីម៉ោង 8 ព្រឹក ដល់ម៉ោង 8:30 យប់ ជារៀងរាល់ថ្ងៃ)។

## តើខ្ញុំគួរតែទទួលចាក់ថ្នាំបង្ការដែរឬទេ ប្រសិនបើខ្ញុំធ្លាប់មានជំងឺ COVID-19 រួចហើយនោះ?

ចាស/បាទ។ អ្នកគួរតែទទួលចាក់ថ្នាំបង្ការ បើទោះបីជាអ្នកធ្លាប់មានជំងឺ COVID-19 រួចហើយក៏ដោយ ពីព្រោះថ្នាំបង្ការនេះអាចជួយទប់ស្កាត់អ្នកពីការឆ្លងជំងឺ COVID-19 ម្តងទៀត។

ការឆ្លងជំងឺ COVID-19 ផ្តល់នូវប្រព័ន្ធការពារខ្លះពីការធ្លាក់ខ្លួនឈឺដោយសារជំងឺ COVID-19 នាពេលអនាគតដែលពេលខ្លះត្រូវបានហៅថា "ប្រព័ន្ធភាពស៊ាំដោយធម្មជាតិ"។ ប៉ុន្តែកម្រិតនៃប្រព័ន្ធការពារដែលមនុស្សទាំងឡាយទទួលបានតាមរយៈការឆ្លងមេរោគ មានភាពខុសគ្នា។ កម្រិតនៃប្រព័ន្ធការពារនេះអាស្រ័យទៅលើថាតើជំងឺរបស់ពួកគេមានកម្រិតស្រាលឬកម្រិតធ្ងន់ធ្ងរ ឬក៏ពេលវេលាដែលបានកន្លងផុតទៅចាប់តាំងពីការឆ្លងជំងឺ COVID-19 ហើយនិងអាយុរបស់ពួកគេ។ មនុស្សទាំងឡាយណាដែលធ្លាប់មានជំងឺ COVID-19 ហើយមិនបានទទួលចាក់ថ្នាំ

បង្ការក្រោយពីពួកគេបានជាសះស្បើយពីជំងឺនោះ ទំនងជាឆ្លងជំងឺ COVID-19 ម្ដងទៀត ច្រើនជាងអ្នកដែលបានទទួលចាក់ថ្នាំបង្ការក្រោយពីពួកគេបានជាសះស្បើយពីជំងឺ។

ប្រសិនបើអ្នកមានជំងឺ COVID-19 នាពេលឥឡូវនេះ សូមរង់ចាំរហូតដល់អ្នកបានជាសះស្បើយ ហើយរយៈពេលនៃការដាក់ខ្លួនឱ្យនៅដាច់ដោយឡែក របស់អ្នកបានបញ្ចប់ ដើម្បីទទួលចាក់ថ្នាំបង្ការ។ ការធ្វើបែបនេះគឺដើម្បីកុំឱ្យអ្នកចម្លងមេរោគទៅកាន់បុគ្គលិកផ្នែកថែទាំសុខភាពនិងអ្នកដទៃទៀតទាំងឡាយ នៅពេលដែលអ្នកទៅទទួលចាក់ថ្នាំបង្ការ។

អ្នកអាចពិចារណាលើការរង់ចាំរហូតដល់រយៈពេល 3 ខែ ក្រោយការកើតជំងឺ COVID-19 លើកដំបូង ដើម្បីចាប់ផ្ដើម ឬបន្តការចាក់លំដាប់ថ្នាំបង្ការ ឬក៏ទទួលចាក់ដូសជំរុញ។ ការធ្វើបែបនេះគឺពីព្រោះតែអ្នកមិនទំនងជានឹងឆ្លងជំងឺ COVID-19 ម្ដងទៀតក្នុងអំឡុងពេល 3 ខែដំបូងក្រោយការឆ្លងមេរោគនោះទេ។ រយៈពេលកាន់តែយូររវាងការឆ្លងមេរោគ និងការទទួលចាក់ថ្នាំបង្ការក៏អាចនឹងធ្វើឱ្យការឆ្លើយតបនៃប្រព័ន្ធភាពស៊ាំរបស់អ្នកបានប្រសើរឡើងផងដែរ។

ប្រសិនបើអ្នកធ្លាប់ធ្លាក់ខ្លួនឈឺដោយមានរោគសញ្ញានៃការរលាកពហុសរីរាង្គចំពោះកុមារ ឬមនុស្សពេញវ័យ (MIS-C ឬ MIS-A) សូមពិភាក្សាជាមួយនឹងគ្រូពេទ្យរបស់អ្នក មុនពេលទទួលចាក់ថ្នាំបង្ការជំងឺ COVID-19។

## តើខ្ញុំអាចទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 ក្នុងពេលតែមួយជាមួយនឹងថ្នាំបង្ការជំងឺផ្សេងទៀតបាន ដែរឬទេ?

ចាស/បាទ។ មនុស្សពេញវ័យ និងកុមារដែលមានអាយុចាប់ពី 6 ខែឡើងទៅ អាចទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 ក្នុងពេលតែមួយជាមួយនឹងថ្នាំបង្ការជំងឺផ្សេងទៀតបាន ដូចជាជំងឺគ្រុនស្វិតដៃជើង (polio) ជំងឺកញ្ជ្រឹល (measles) ជំងឺក្អកមាន់ (whooping cough) និងជំងឺគ្រុនផ្ដាសាយធំ (flu) ផងដែរ។ ប្រសិនបើកូនរបស់អ្នកទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 នៅកន្លែងដែលមិនមានផ្ដល់ថ្នាំបង្ការជំងឺផ្សេងទៀតដែលពួកគេត្រូវការទេនោះ អ្នកអាចទៅកាន់ទីតាំងផ្សេងមួយទៀត ដើម្បីទទួលចាក់ថ្នាំបង្ការទាំងនោះនៅពេលណាក៏បាន។ មិនចាំបាច់រង់ចាំចាក់ថ្នាំបង្ការនៅពេលផ្សេងគ្នានោះទេ។

## តើខ្ញុំអាចទទួលបាននីតិវិធីផ្នែកសុខភាព ឬការធ្វើតេស្តត្រួតពិនិត្យតាមទម្លាប់បានដែរឬទេ ប្រសិនបើខ្ញុំទើបតែទទួលចាក់ថ្នាំបង្ការជំងឺ COVID-19?

នីតិវិធីផ្នែកសុខភាព ឬការត្រួតពិនិត្យជំងឺតាមទម្លាប់ភាគច្រើនអាចធ្វើទៅបានមុន ឬក្រោយពេលទទួលចាក់ថ្នាំបង្ការជំងឺ COVID-19។

កំណត់សម្គាល់៖ ប្រសិនបើអ្នកដល់ពេលកំណត់ត្រូវថតឆ្លុះត្រួតពិនិត្យសុដន់តាមទម្លាប់ និងបានទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 នាពេលថ្មីៗនេះ សូមសាកសួរទៅកាន់គ្រូពេទ្យរបស់អ្នក ថាតើអ្នកគួរតែរង់ចាំរយៈពេលយូរប៉ុណ្ណា មុនពេលដែលអ្នកអាចថតឆ្លុះបាននោះ។ មនុស្សទាំងឡាយដែលបានទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 អាចនឹងមានហើមកូនកណ្ដុរ (ហៅថា lymphadenopathy) នៅក្លៀកជិតកន្លែងដែលពួកគេបានទទួលចាក់ថ្នាំ។ ការហើមនេះគឺជាសញ្ញាធម្មតាដែលថារាងកាយកំពុងកសាងប្រព័ន្ធការពារប្រឆាំងនឹងជំងឺ COVID-19។ ការហើមជាបណ្ដោះអាសន្ននេះ អាចបណ្ដាលឱ្យមានភាពមិនត្រឹមត្រូវក្នុងការពិនិត្យមើលលទ្ធផលនៃការថតឆ្លុះសុដន់ ដូច្នេះការប្រាប់ទៅដល់បុគ្គលិកអំពីការចាក់ថ្នាំបង្ការរបស់អ្នក គឺជាការសំខាន់។ សម្រាប់ព័ត៌មានលម្អិតបន្ថែម សូមមើល ដំបូន្មានសម្រាប់ស្ត្រីដែលទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 របស់សមាគមន៍នៃការថតឆ្លុះសុដន់ (Society of Breast Imaging)។

ថ្នាំបង្ការជំងឺ COVID-19 ក៏អាចប៉ះពាល់ដល់លទ្ធផលនៃការធ្វើតេស្តស្វែងរកជំងឺរបេង (TB) មួយចំនួនផងដែរ សូមមើលគេហទំព័រ ការទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 និងនីតិវិធីផ្នែកសុខភាពផ្សេងទៀត របស់មជ្ឈមណ្ឌលគ្រប់គ្រងនិងទប់ស្កាត់ជំងឺឆ្លង (CDC)។

## តើខ្ញុំគួរតែរៀបចំយ៉ាងដូចម្ដេចខ្លះ សម្រាប់ដំណើរទៅតាមការណាត់ជួប ដើម្បីទទួលចាក់ថ្នាំបង្ការ?

- ចូរចងចាំថាត្រូវនាំយកឯកសារដែលតម្រូវចាំបាច់ ព្រមទាំងអាសយដ្ឋានអ៊ីម៉ែល ឬលេខទូរស័ព្ទចល័តរបស់អ្នកផងដែរ ប្រសិនបើអ្នកមាន។ ប្រសិនបើអ្នកបានធ្វើការណាត់ជួប សូមអានព័ត៌មាននៅក្នុងអ៊ីម៉ែលដែលបញ្ជាក់អំពីការណាត់ជួបនោះ។ ប្រសិនបើអ្នកមានសំណួរផ្សេងៗ ការកត់ត្រាសំណួរទាំងនោះអាចជាការមានប្រយោជន៍។

- ប្រសិនបើអ្នកមិនប្រើប្រាស់ថ្នាំដែលមិនចាំបាច់មានវេជ្ជបញ្ជា (ដូចជា ថ្នាំ ibuprofen ឬថ្នាំ aspirin ឬក៏ថ្នាំ acetaminophen) ជាទៀតទាត់ទេនោះ សូមកុំប្រើប្រាស់ថ្នាំទាំងនេះមុនពេលអ្នកទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 ដើម្បីព្យាយាមទប់ស្កាត់ផលប៉ះពាល់ផ្សេងៗ។ ប៉ុន្តែ ប្រសិនបើអ្នកប្រើប្រាស់ថ្នាំទាំងនេះជាទៀងទាត់សម្រាប់មូលហេតុផ្សេងៗទៀត អ្នកគួរតែបន្តប្រើប្រាស់ថ្នាំទាំងនេះមុនពេលអ្នកទទួលចាក់ថ្នាំបង្ការ។
- **នាំយកម៉ាស់ អាហារសម្រន់ និងទឹកទៅជាមួយ។** ប្រសិនបើអ្នកធ្វើដំណើរទៅកាន់ទីតាំងដែលនៅបរិវេណខាងក្រៅអគារ នៅថ្ងៃដែលមានអាកាសធាតុក្តៅគួរសម សូមពាក់មួកនិងសម្លៀកបំពាក់ស្តើងៗ។
- សម្រាប់គន្លឹះក្នុងការនិយាយជាមួយកូនរបស់អ្នកអំពីការទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 ហើយនិងត្រៀមខ្លួនពួកគេឱ្យបានរួចរាល់ក្នុងការទទួលចាក់ថ្នាំបង្ការនោះ សូមមើលចំណុច ការទទួលចាក់ថ្នាំបង្ការសម្រាប់កុមារ នៅក្នុងបញ្ជី សំណួរដែលបានសួរជាញឹកញាប់អំពីថ្នាំបង្ការជំងឺ COVID-19 របស់នាយកដ្ឋានសុខភាពសាធារណៈនៃខោនធី LA (LAC DPH)។

## តើខ្ញុំគួរតែធ្វើអ្វីខ្លះ ក្រោយពីទទួលចាក់ថ្នាំបង្ការរួច?

- ត្រូវប្រាកដថាអ្នកផ្តល់សេវាកម្មចាក់ថ្នាំបង្ការរបស់អ្នក បានបំពេញព័ត៌មានថ្មីបំផុតទៅលើកាតចាក់ថ្នាំបង្ការរបស់អ្នក (ឬផ្តល់កាតមួយដល់អ្នក ប្រសិនបើនោះជាការទទួលចាក់ថ្នាំបង្ការដូសទីមួយ)។
- មុនពេលដែលអ្នកចាក់ចេញពីទីតាំងចាក់ថ្នាំបង្ការ សូមធ្វើការណាត់ជួបសម្រាប់ការទទួលចាក់ដូសថ្នាំបង្ការបន្ទាប់ទៀត ប្រសិនបើអ្នកត្រូវការ។
- ត្រូវស្វែងយល់ថាអ្នកអាចនឹងជួបប្រទះ ផលប៉ះពាល់ផ្សេងៗ ក្រោយពីការទទួលចាក់ថ្នាំបង្ការរួច។ ព្រឹត្តិការណ៍អវិជ្ជមាន ហើយនិងប្រតិកម្មឬការទាស់កម្រិតធ្ងន់ធ្ងរ គឺកម្រនឹងកើតមាន។ ដើម្បីធ្វើការរាយការណ៍អំពីផលប៉ះពាល់ផ្សេងៗ អ្នកអាចចុះឈ្មោះនៅក្នុងកម្មវិធី v-safe។

## តើខ្ញុំអាចទទួលបានព័ត៌មានបន្ថែមនៅទីណា?

- ដើម្បីបោះពុម្ព ឬមើលសំណួរដែលបានសួរជាញឹកញាប់នេះ ឬសំណួរដែលបានសួរជាញឹកញាប់ផ្សេងទៀតទាក់ទងនឹងប្រធានបទថ្នាំបង្ការជំងឺ COVID-19 សូមស្កេនកូដ QR នេះ ឬចូលទៅកាន់គេហទំព័រ សំណួរដែលបានសួរជាញឹកញាប់ទាក់ទងនឹងថ្នាំបង្ការជំងឺ COVID-19។
- គេហទំព័រ VaccinateLACounty.com - រួមទាំងគេហទំព័រ កាលវិភាគនៃការចាក់ថ្នាំបង្ការជំងឺ COVID-19 ដែលមានរូបភាពក្រាហ្វិចដើម្បីបង្ហាញនូវពេលណាដែលដូសនីមួយៗដល់ពេលកំណត់អាចទទួល និងព័ត៌មានស្តីពី វិធីទទួលចាក់ថ្នាំបង្ការ។
- គេហទំព័រការទទួលចាក់ ថ្នាំបង្ការជំងឺ COVID-19 របស់មជ្ឈមណ្ឌលគ្រប់គ្រងនិងទប់ស្កាត់ជំងឺឆ្លង (CDC)។
- ចូរពិគ្រោះជាមួយនឹងគ្រូពេទ្យរបស់អ្នក ប្រសិនបើអ្នកមានសំណួរផ្សេងៗ។